# ចម្លាក់ឧមាមហេស្វរៈ

ចម្លាក់ឧមាមហេស្វរៈ ជារឿងបង្ហាញពីទេពព្រះសិវៈ និងព្រះនាងឧមាគង់លើគោននន្ទិន មានព្រះហស្ត២ ខាងស្តាំកាន់ត្រីសូល ឬផ្កាំ និងដៃឆ្វេងដាក់លើស្មាព្រះនាងឧមា។ ចម្លាក់ឧមាមហេស្វរៈ មានបង្ហាញព្រះហស្ត៤ ព្រហស្ត១កាន់ពូថៅ ព្រះកាយរុំស្បែកសត្វ និងពេលខ្លះព្រហស្តស្តាំកាន់ត្រីសូល។[១] ចម្លាក់ក្នុងសិល្បៈខ្មែរ បង្ហាញព្រះនាងឧមាអង្គុយលើគោននន្ទិនផ្នែកខាងក្រោយ និងព្រះហស្តកាន់ផ្កាឈូក។ ការបង្ហាញរូបព្រះសិវៈ និងព្រះនាងឧមាក្នុងសាសនាហិណ្ឌូ ជារឿងកើតឡើងដំបូងមួយក្នុងចំណោមរឿងសិវៈមហាស្វរមុតិទាំង២៩ ដើម្បីបង្ហាញការបង្កើតអ្វីៗថ្មីដំបូងរបស់គម្ពីសិវៈបុរាណ។ ចម្លាក់បង្ហាញរូបព្រះសិវៈមានព្រះភក្ត្រ និងព្រះហស្តច្រើនដូចជា ព្រះសទាសិវៈជាដើម គឺដើម្បីបង្ហាញពីអំណាច និងសមត្ថភាពដ៏ធំធេងរបស់ព្រះសិវៈ ក្នុងការបំពេញភារៈកិច្ចច្រើនក្នុងពេលដំណាលគ្នា។ ចម្លាក់ឧមាមហេស្វរៈ មានឆ្លាក់បង្ហាញគង់លើគោននន្ទិន និងមានលើបល្ល័ង្ក ហើយមានកាយវិការខុសៗគ្នាខ្លះដូចជា ព្រះហស្តស្តាំដាក់លើភ្លៅ កាន់អង្កាំ និងកាន់ត្រីសូល ចំណែកព្រះហស្តឆ្វេងរបស់ព្រះសិវៈលេចចេញពីលើស្មា ឬអោបចង្កេះព្រះនាងឧមា។

ពេលខ្លះមានឆ្លាក់រូបអមជុំវិញព្រះឧមាមហេស្វរៈនេះ រួមមានព្រះគណេស ព្រះស្កន្ទ ព្រះវិស្ណុ ព្រះព្រហ្ម និងឥសី។ ចម្លាក់រូបឧមាមហេស្វរៈ ឆ្លុះបញ្ចាំងពីរឿងទេវកថាទាក់ទងគ្រួសារ និងការអនុវត្តយោហ្គា ដើម្បីគ្រប់គ្រងការត្រាស់ដឹងរបស់ទេព។ ពេលខ្លះនៅតណ្ឌាចម្លាក់នេះ ឆ្លាក់បន្ថែមរូបទេពរាំនៅក្បែរព្រះបាទរបស់ព្រះសិវៈ។ ព្រះសិវៈឆ្លាក់រួមគ្នាជាមួយព្រះនាងឧមា គឺតំណាងឱ្យសារៈសំខាន់ទម្រង់ទេពភេទស្រី ទំនាក់ទំនងជិតស្និទ្ធ និងប្រកបដោយសេចក្តីស្រឡាញ់ ដែលតំណាងឱ្យកម្លាំងបុរស និងស្ត្រី។ តាមចម្លាក់ឧមាមហេស្វរៈនៅក្នុងសិល្បៈខ្មែរ គឺបង្ហាញជា២ទម្រង់ និងឆ្លាក់ជាសិល្បៈ៤ប្រភេទផ្សេងៗគ្នា។

ចំណែកចម្លាក់ឧមាមហេស្វរៈនៅរាជធានីកោះកេរមាន២ មួយជាចម្លាក់ទោលនៅខ្លោងទ្វារចូលទី២ប្រាសាទធំ[២] និងផ្សេងទៀតឆ្លាក់លើថ្មធម្មជាតិ នៅខាងត្បូងត្រពាំងខ្នារ។

---

[១] Rovenda, 2005: 163

[២] https://collection.efeo.fr

អត្ថបទដោយ៖ លោក ជុ ជុន

ប៉ុន្តែចម្លាក់នៅខ្លោងទ្វារទី២នេះ បង្ហាញជាចម្លាក់ទោល មានក្បាច់ល្អវិចិត្រ និងទំហំធំជាងសម័យក្រោយរាជ្យព្រះបាទជ័យវរ្ម័នទី៤ ដែលភាគច្រើនឆ្លាក់នៅលើផ្តែរ ហោជាង ប្រាសាទ សីមាថ្មភក់តូចៗ និងថ្មធម្មជាតិប៉ុណ្ណោះ។ ចម្លាក់ទោល ឧមាមហេស្វរៈ គឺពុំពេញនិយមឆ្លាក់ទេនៅសម័យមុនរាជ្យព្រះបាទជ័យវរ្ម័នទី៤។ ប៉ុន្តែចម្លាក់នេះប្រទះឃើញមានឆ្លាក់លើពើងត្បាល់មាន២ ចម្លាក់សិវៈ និងនាងឧមាគង់លើគោនន្ទិន និងផ្សេងមួយទៀតខូចខាតខ្លាំងនៅសល់តែរូបព្រះសិវៈគង់លើគោនន្ទិន។ ចំណែកចម្លាក់ឧមាមហេស្វរៈនៅត្រពាំងខ្នារ គឺដូចគ្នាចម្លាក់នៅពើងត្បាល់ភ្នំគូលែន ដែលឆ្លាក់លើថ្មភក់ធម្មជាតិ។

ប្រភេទចម្លាក់ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៤ ឆ្លាក់ជាបដិមាទោល ឧមាមហេស្វរៈនៅច្រកចូលទី២ប្រាសាទធំ គឺជាចម្លាក់១ក្នុងរឿងសិវៈមហាស្វរមុតិទាំង២៥ ដែលបង្ហាញភាគច្រើននៅប្រាសាទរួម (ប្រាសាទធំកោះកេរ) (រូបលេខ១)។ ចម្លាក់ឧមាមហេស្វរៈ មានឆ្លាក់នៅលើផ្ទាំងថ្មភក់ធម្មជាតិនៅភ្នំគូលែនសតវត្សទី៩នៃគ.ស និងប្រាសាទខ្នារសតវត្សទី១០នៃគ.ស គឺមានអមដោយរូបឥសី ព្រះវិស្ណុផ្ទុំលើនាគ ព្រះព្រហ្ម ព្រះគណេស និងទេពផ្សេៗទៀត (រូបលេខ២,៣)។



**រូបលេខ១៖** ឧមាមហេស្វរៈនៅខ្លោងទ្វារទី២ប្រាសាទធំ (EFEO_CAM11297)





**រូបលេខ២,៣៖** ឧមាមហេស្វរៈអមដោយទេពផ្សេងៗ និងឥសី នៅត្រពាំងខ្នារខាងឆ្វេង និងនៅភ្នំគូលែនខាងស្តាំ

ចម្លាក់ឧមាមហេស្វរៈមួយប្រភេទទៀត ឆ្លាក់លើផ្ទាំងថ្មភក់តូចៗ ដូចជាបង្គោលសីមា ដែលមានដង្កល់តាមប្រាសាទដូចជានៅប្រាសាទត្រពាំងរុន ជិះលើគោនន្ទិន និងមួយទៀតអង្គុយលើបល្ល័ង្កមានរូបគោនន្ទិន ក្នុងសតវត្សទី១០គ.ស។ ចម្លាក់មកពីប្រាសាទត្រពាំងរុន បង្ហាញរូបព្រះសិវៈកាន់ត្រីសូរនៅដៃស្តាំ និងអោបស្មារព្រះនាងឧមា។ ចំណែក

អត្ថបទដោយ៖ លោក ជុ ជុន

ព្រះនាងឧមាដៃស្តាំអោបចង្កេះព្រះសិវៈ និងឆ្វេងកាន់ផ្កាឈូក ដែលជាចម្លាក់ស្រដៀងចម្លាក់នៅឥណ្ឌា (រូបលេខ៤, ៥)។




រូបលេខ៤ ,៥៖ ចម្លាក់ឧមាមហេស្វរៈ លើសីមាមកពីប្រាសាទត្រពាំងរុនស.វទី១០គ.ស។
ចម្លាក់បង្ហាញគង់លើគោ និងលើបល្ល័ង្គ(ប្រភព: បញ្ជីរអភិរក្សដ្ឋានអង្គរ)

ចម្លាក់នៅលើផ្តែរប្រាសាទមឿងតាំ[៣]នៅចុងសតវត្សទី១០ និងដើមទី១១គ.ស និងនៅលើហោជាងតួប៉មខាងត្បូង និងលើហោជាងថែវបន្ទប់វែងរបស់ប្រាសាទបន្ទាយស្រីនៅចុងស.វទី១០គ.ស។ ផ្តែរប្រាសាទមឿងតាំ គឺជាចម្លាក់ល្អ ដែលបង្ហាញសិវៈ និងឧមាគង់លើគោនន្ទិន អមដោយព្រះកក្រូទេព២សង្ខាង និងស្ថិតនៅកណ្តាលជង់ធ្នូលើរូបរាហូ (រូបលេខ ៦)។ ចម្លាក់នៅលើហោជាងប្រាសាទបន្ទាយស្រីមួយស្ថិតនៅតួប៉មខាងត្បូង និងផ្សេង១ទៀតស្ថិតនៅថែវបន្ទប់វែង ដែលឆ្លាក់ទេពឧមាតូចព្រះហស្តខាងស្តាំអោបដៃឬចង្កេះព្រះសិវៈនៅចុងសតវត្សទី១០គ.ស (រូបលេខ ៧,៨)។ ចម្លាក់នេះពេញនិយមឆ្លាក់ច្រើនសម័យក្រោយរាជព្រះបាទជ័យវរ្ម័នទី៤ តែភាគច្រើនឆ្លាក់ច្រើននៅលើផ្តែរ និងនៅលើហោជាង។

---

[៣] ប្រាសាទមឿងតាំ សព្វថ្ងៃស្ថិតនៅខេត្តបុរីរាម(ប្រទេសថៃ) នៅចុងស.វទី១០គ.ស និងដើមស.វទី១១គ.ស

អត្ថបទដោយ៖ លោក ជុ ជុន





**រូបលេខ៦៖** ចម្លាក់នៅលើផ្តែរប្រាសាទមឿងតាំបង្ហាញរូប២អមសង្ខាងសិវៈ និងឧមា

**រូបលេខ៧,៨៖** ចម្លាក់ឧមាមហេស្វរនៅលើហោជាងតួប៉មខាងត្បូង និងថែវបន្ទប់វែងប្រាសាទបន្ទាយស្រីចុងស.វទី១០។

ប៉ុន្តែនៅសម័យក្រោយរាជ្យព្រះបាទជ័យវរ្ម័នទី៤ បានបន្តឆ្លាក់រូបឧមាមហេស្វរៈ លើហោជាងថែវបន្ទប់វែងប្រាសាទបន្ទាយស្រី ឆ្លាក់លើបល្ល័ង្ក និងឆ្លាក់លើផ្តែរផ្សេងទៀតជាច្រើន នៅចុងស.វទី១០ និងទី១១គ.ស ឬខ្លះស្ថិតក្នុងរចនាបថបាពួន។ ចម្លាក់នេះពេញនិយមឆ្លាក់នៅលើផ្តែរប្រាសាទច្រើននៅក្នុងសតវត្សទី១១គ.ស ដែលមានឆ្លាក់លាយរូបព្រះឥន្ទ្រ ឥសី និងវិស្ណុជាដើម។ យ៉ាងហោចណាស់មានផ្តែរចំនួន៥ ឆ្លាក់បង្ហាញរូបឧមាមហេស្វរៈ មួយឆ្លាក់រូបព្រះឥន្ទ្រជិះលើដំរីក្បាល៣ នៅកណ្តាលដងផ្ទូរលើរូបរាហូ និងផ្នែកខាងលើផ្តែរមានឆ្លាក់រូបឧមាមហេស្វរៈអមដោយឥសីម្ខាង៦ និងគ្រុឌ១ (រូបលេខ៩,១០,១១)។ ផ្តែរប្រាសាទមឿងតាំ បង្ហាញរូបឧមាមហេស្វរៈគង់លើគោនៅកណ្តាលលើរូបរាហូ និងបង្ហាញរូងទេព២លេចព្រះកក្រចេញសង្ខាង។ ចម្លាក់ផ្តែរ២ផ្សេងទៀត មានឆ្លាក់ឧមាមហេស្វរៈ នៅកណ្តាលដងផ្ទូរលើរាហូ អមដោយឥសីសង្ខាង៨ ស្ថិតក្នុងសតវត្សទី១១គ.ស។





**រូបលេខ៩,១០,១១៖** ចម្លាក់ផ្តែរ បង្ហាញព្រះឧមាមហេស្វរៈ អមដោយទេពផ្សេងៗ ឬឥសីសំពះសង្ខាង

អត្ថបទដោយ៖ លោក ជុ ជុន

ចម្លាក់ផ្តែរសំខាន់មួយផ្សេងទៀត គឺផ្តែរមកពីប្រាសាទថ្នល់ដើង ស្ថិតក្នុងសតវត្សទី១១គ.ស គឺឆ្លាក់បង្ហាញរូបទេពជាច្រើនអមរូបឧមាមហេស្វរៈនៅកណ្តាល។ ចម្លាក់ឧមាមហេស្វរៈអមដោយព្រះវិស្ណុឈរលើគ្រុឌ និងនរសឹង្ហនៅខាងឆ្វេង ព្រះព្រហ្មឈរលើផ្កាឈូកនៅខាងស្តាំ ទេពផ្សេងទៀតអមសង្ខាង និងរូបឥសីនៅផ្នែកខាងលើផ្តែរ (រូបលេខ១២)។ ចម្លាក់ផ្តែរប្រាសាទថ្នល់ដើងនេះ គឺឆ្លាក់ល្អ និងប្រទះឃើញតែមួយក្នុងសិល្បៈនៅសតវត្សទី១១គ.ស ដែលឆ្លាក់បង្ហាញរូបទេពអមច្រើនលើផ្តែរតែមួយ។

ក្រៅពីចម្លាក់ទោល និងនៅលើផ្តែរ ចម្លាក់ឧមាមហេស្វរៈ និងចម្លាក់មានកាយវិការផ្សេងមួយទៀតក្នុងសតវត្សទី១២គ.ស គឺឆ្លាក់នៅប្រាសាទវត្តភូ លើហោជាងខាងត្បូង នៅប្រាសាទព្រះវិហារនៅច្រកចូលខ្លោងទ្វារទី៣ ហោជាងខាងត្បូង នៅប្រាសាទបន្ទាយសំរែ លើហោជាង និងប្រាសាទអំពិល ដែលឆ្លាក់រូបឧមាមហេស្វរ គង់លើគោនន្ទិនត្រឡប់បែរមកខាងស្តាំវិញ (រូបលេខ១៣ ដល់១៦)។ ចម្លាក់ឧមាមហេស្វរក្នុងសម័យនេះ បង្ហាញទេពប្រុសស្រីផ្សេងទៀតអម កាន់ផ្ចិត និងឆ័ត្រ និងឥសី ដែលទេពខ្លះបង្ហាញកាយវិការសំពះគោរព។ ចម្លាក់ឧមាមហេស្វរៈផ្សេងទៀត នៅលើហោងជាងប្រាសាទកំផែងណាយ ប្រាសាទកំផែងយៃ និងប្រាសាទបាយ័ន នៅបន្តឆ្លាក់រហូតដល់សតវត្សទី១២ និងទី១៣គ.ស (រូបលេខ១៧ ដល់១៩)។ ចម្លាក់នេះក្នុងសតវត្សទី១២ និង១៣គ.ស នៅតែបន្តឆ្លាក់អមដោយទេពផ្សេងៗ និងរូបឥសីសំពះសង្ខាង ស្រដៀងចម្លាក់នៅសតវត្សទី១១គ.សដែរ ប៉ុន្តែបង្ហាញព្រះសិរៈកាន់ត្រីសូរខ្លះ និងដាក់ព្រះហស្តលើជង្គង់ខាងស្តាំ។



**រូបលេខ១២៖** ចម្លាក់ផ្តែររឿងឧមាមហេស្វរៈ នៅប្រាសាទព្រៃថ្នល់ដើង ក្នុងស.វទី១១គ.ស (ប្រភព៖ EFEO_PINV9546 INVLU8254 )

អត្ថបទដោយ៖ លោក ជុ ជុន






***រូបលេខ១៣ដល់១៦៖*** *ចម្លាក់ឧមាមហេស្វរនៅលើហោជាងប្រាសាទអំពិល ប្រាសាទវត្តគូ ប្រាសាទបន្ទាយសំរ៉ែ និងប្រាសាទព្រះវិហារច្រកចូលទី៣ហោជាងខាងត្បូង*





***រូបលេខ១៧,១៨៖*** *ហោជាងបង្ហាញចម្លាក់សិវៈ និងឧមានៅប្រាសាទកំផែងយៃនិងកំផែងណាយ ស្ថិតនៅប្រទេសថៃសព្វថ្ងៃ (ប្រភព៖* Roveda, 2005)។

***រូបលេខ១៩៖*** *ចម្លាក់សិវៈនិងឧមាមហេស្វរៈនៅប្រាសាទបាយ័ន ក្នុងស.វទី១៣គ.ស*

## *សង្ខេប*

*អត្ថបទនេះចង់បង្ហាញចម្លាក់រូបឧមាមហេស្វរៈក្នុងសិល្បៈខ្មែរ ដែលឆ្លាក់បង្ហាញនៅលើថ្មធម្មជាតិ ចម្លាក់ទោល និងនៅផ្តែរមួយចំនួនប៉ុណ្ណោះ។ ចម្លាក់ឧមាមហេស្វរៈឆ្លាក់មាន២ទម្រង់ដូចជា ឆ្លាក់ជិះលើយានជំនិះគោនន្ទិន និងលើបល្ល័ង្ក។ ចម្លាក់ឧមាមហេស្វរៈ គឺជារឿងមួយក្នុងចំណោម២៥ របស់រឿងមហាស្វរៈមុរតិ ដែលមានឆ្លាក់ច្រើនជាងគេនៅប្រាសាទរួមកោះកេរ ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៤។ ប៉ុន្តែចម្លាក់ប្រភេទនេះប្រហែលផ្តើមឆ្លាក់តាំងនៅពើងត្បាលក្ពុគូលែន ផ្នែកឦសានប្រាសាទចិន នៅដើមសម័យអង្គរ។ ចម្លាក់ឧមាមហេស្វរៈនេះ មិនដែលប្រទះឃើញមានឆ្លាក់នៅសម័យមុនអង្គរទេ ទាំងនៅលើរចនាសម្ព័ន្ធសំណង់ប្រាសាទ ហោជាង ផ្តែរ និងបដិមាទោល។ នៅដើមសម័យអង្គរ ចម្លាក់ឧមាមហេស្វរៈ ចាប់ផ្តើមនិយមឆ្លាក់នៅលើពើង និងថ្មធម្មជាតិ ដូចជានៅពើងត្បាល់ភ្នំគូលែនជាដើម ប៉ុន្តែពុំទាន់ឃើញមានចម្លាក់ទោលនោះទេ។ រហូតដល់រាជ្យរបស់*

*អត្ថបទដោយ៖ លោក ថុ ថុន*

ព្រះបាទជ័យវរ្ម័នទី៤ ទើបមានចម្លាក់ទោលរូបព្រះឧមាមហេស្វរៈ ដែលតម្កល់នៅខ្លោងទ្វារទី២របស់ប្រាសាទធំ និងមានឆ្លាក់នៅលើថ្មធម្មជាតិ ផ្នែកខាងត្បូងត្រពាំងខ្លារក្នុងស.វទី១០គ.ស។ ម្យ៉ាងទៀតចម្លាក់ឧមាមហេស្វរៈនេះ មានឆ្លាក់នៅលើបន្ទះសីមា ពេញនិយមឆ្លាក់ ក្នុងសតវត្សទី១០គ.ស រហូតដល់ទី១១ គ.ស។ ចំណុចទី៣ ផ្សេងទៀតចម្លាក់ឧមាមហេស្វរៈ មានឆ្លាក់នៅលើផ្តែរប្រាសាទតាំងពីសតវត្សទី១០គ.ស ឆ្លាក់ច្រើននៅស.វទី១១គ.សនៅលើផ្តែរ ឬបន្តឆ្លាក់រហូតដល់ស.វទី១២គ.ស និងសម័យបាយ័នស.វទី១៣គ.ស ភាគច្រើននៅលើហោជាង។ ការបង្ហាញចម្លាក់ឧមាមហេស្វរៈផ្សេងទៀត គឺឃើញឆ្លាក់អមដោយទេពផ្សេងៗដូចជាព្រះព្រហ្ម ព្រះវិស្ណុ ព្រះគណេស និងឥសីក្នុងកាយវិការសំពះ។

## ឯកសារយោង


Roveda, V., 2005. *Images of the gods: Khmer mythology in Cambodia, Thailand and Laos*. Bangkok:River.

https://collection.efeo.fr


AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION